# ជំងឺផ្កាកូលាប *(Pink Disease)*

## ១.លក្ខណៈទូទៅរបស់ជំងឺ

ជំងឺផ្កាកូលាបត្រូវបានគេរកឃើញជាលើកដំបូងនៅប្រទេសឥណ្ឌូនេស៊ី ក្នុងឆ្នាំ១៩០១ និងបន្ទាប់មកនៅក្នុងប្រទេសឥណ្ឌាក្នុងឆ្នាំ១៩០៨។ ជំងឺនេះក៏មានកើតផងដែរនៅលើដើមតែ កាកាវ ស្វាយ ស្វាយចន្ទី ខ្នុរ ក្រូចឆ្មារ។ល។ ជំងឺផ្កាកូលាបជាជំងឺមួយដ៏ធ្ងន់ធ្ងរដែលកើតនៅលើមែកកៅស៊ូ ជាពិសេសកើតនៅលើជំពាមមែកដែលបង្កឡើងដោយផ្សិតឈ្មោះ *Corticium salmonicolor*។ ជំងឺនេះ កើតនៅលើដើមកៅស៊ូអាយុចាប់ពី៣ឆ្នាំ ដល់អាយុ១២ឆ្នាំ គឺនៅពេលដែលកញ្ចុំស្លឹកប៉ះគ្នាពីដើមមួយទៅដើមមួយ ដែលធ្វើឲ្យម្លប់និងពន្លឺចូលពុំបានគ្រប់គ្រាន់។ ការធ្លាក់ភ្លៀងជាប់ៗគ្នានៅរដូវវស្សា សំណើមខ្ពស់ និងសីតុណ្ហភាពទាប ជាមូលហេតុកើតឡើងនិងរាលដាលជំងឺនេះយ៉ាងឆាប់រហ័ស។

ជំងឺនេះកើតឡើងផងដែរនៅលើដើមនិងផ្ទាំងមុខចៀរកៅស៊ូ។ ចំពោះមែកកៅស៊ូដែលមានពណ៌សម្បុរត្នោត ក្នុងដំណាក់កាលដែលមានភ្លៀងធ្លាក់ជាប់ៗគ្នា និងទទួលសំណើមរយៈពេលយូរងាយទទួលរងការឆ្លងរីករាលដាលនៃជំងឺនេះដោយស្ប៉ូរផ្សិត ដែលជាភ្នាក់ងារបង្កជំងឺតាមរយៈខ្យល់ និងទឹកភ្លៀង។ នៅពេលដើមកៅស៊ូទទួលរងជំងឺនេះ ធ្វើឲ្យមានការបំផ្លាញសំបក បាត់បង់មែក និងកញ្ចុំស្លឹក ដែលជាមូលហេតុធ្វើឲ្យដើមកៅស៊ូចុះខ្សោយ ពន្យារយៈពេលផ្តល់ផល២ឆ្នាំ ទិន្នផលធ្លាក់ចុះពី ១៤,៥ - ៦៧,៥% និងជួនកាលធ្វើឲ្យដើមកៅស៊ូងាប់ទាំងស្រុង។

## ២. រោគសញ្ញាជំងឺ

ស្ប៉ូរ២បែបផ្សេងគ្នា ដែលសង្កេតឃើញមានពេលអាកាសធាតុសើមខ្លាំង៖

**ក. ដំណាក់កាលទី១ (Corticium stage)**

ជាការកកើតនៃស្រទាប់ក្រម៉ាពណ៌ផ្កាកូលាបហើយឆ្លងរាលដាលតាមខ្យល់។ ការកើតមានឡើងនៃសរសៃឆ្មារតូចៗ (មីសេលីយ៉ូម) លើផ្ទៃសំបកជាសញ្ញាសម្គាល់នៃការចាប់ផ្តើមនៃជំងឺនេះ។ សរសៃឆ្មារតូចៗនេះ មានរាងជាសំបុកពីងពាងពណ៌សនិងចាំងពណ៌ផ្លេកៗ ពេលត្រូវពន្លឺថ្ងៃ នៅពេលសំបកស្ងួត។

**ខ. ដំណាក់កាលទី២ (Necator stage)**

រលួយទៅជាពណ៌ស្លាទុំ និងឆ្លងរាលដាលតាមការសាចហូររបស់ទឹកភ្លៀងក្នុងពេលដែល មានភ្លៀងធ្លាក់ជោគជាំ។ ក្នុងលក្ខខណ្ឌអំណោយផល ជំងឺនេះចាប់ផ្តើមជ្រៀតចូលទៅក្នុងសំបក និងទៅក្នុងសាច់ឈើដែលបណ្តាលឲ្យខូចខាតធ្ងន់ធ្ងរដល់ប្រព័ន្ធជាលិកាក្នុងដើមកៅស៊ូ។ ជាលទ្ធផល កន្លែងកើតជំងឺនោះ ហូរទឹកជ័រជាទម្រង់ឆ្នូតៗពណ៌សនិងប្រែជាពណ៌ខ្មៅ ហើយបន្ទាប់មកធ្វើឲ្យសំបកដំបៅរលួយ ប្រេះ និងស្ងួតរបើកដែលធ្វើឲ្យយើងមើលឃើញសាច់ឈើ។ នៅក្នុងដំណាក់កាលនោះដំណឹកជញ្ជូនទឹកនិងរុក្ខរសត្រូវបានរំខាន អាស្រ័យដោយប្រព័ន្ធជាលិកាខូចខាត។ ពេលនោះកន្សោមស្លឹកផ្នែកលើមែកដែលកើតជំងឺប្រែទៅជាពណ៌លឿង និងបន្ទាប់មកទៅជាក្រៀមហើយ ស្លឹកក្រៀមនោះស្ថិតនៅជាប់លើមែក។ មែកថ្មីត្រូវបានដុះចេញពីផ្នែកខាងក្រោមនៃកន្លែងដែលកើតជំងឺនោះ។

ជាការពិតណាស់ ជំងឺនេះមិនអាចជាដោយឯកឯងបានទេ នៅរដូវប្រាំងកន្លែងកើតជំងឺមានសភាពប្រែទៅជាក្រៀមហាក់បីដូចជាជំងឺនេះបានជាសះស្បើយ តែតាមពិតផ្សិតនៃជំងឺនេះនៅរស់សម្ងំនៅទីនោះ ហើយនៅពេលមានលក្ខខណ្ឌសមប្រកប ជំងឺនេះនឹងកើតមានឡើងវិញ។ ដូច្នេះ ទាមទារនូវការបង្ការនិងព្យាបាលទាន់ពេលវេលា។

- ក្លូនធន់ជំងឺ៖ PB 86, PR 107, GT 1, PB 260, …
- ក្លូនងាយឆ្លងជំងឺ៖ RRIM 600 ,Tjir1 , PB 217, PB 311, PB 314 …



*រូបភាពទី១៖ ការកើតជំងឺផ្កាកូលាបលើដើម ផ្ទាំងចៀរ និងដង្កៀបមែក*

## ៣. ការការពារនិងការព្យាបាល

### ក.ការការពារ

- កាត់រំលោះមែកខ្លះ ក្នុងករណីមានមែកច្រើន ដើម្បីងាយស្រួលដល់ការចេញចូលនៃខ្យល់និងពន្លឺថ្ងៃក្នុងចម្ការឲ្យបានគ្រប់គ្រាន់
- ជ្រើសរើសក្លូនកៅស៊ូដែលធន់ទ្រាំជំងឺនេះមកដាំដុះ

- បាញ់ថ្នាំបង្ការប័រដូរ ១% តាមសមាមាត្រ៖

* សាច់ជូរខៀវ ១ គ.ក្រ + កំបោរស ២ គ.ក្រ + ទឹក១០០លីត្រ ឬ

* ថ្នាំ Validamycine 5% ចំនួន ៣០ - ៥០ មីលីលីត្រ + ទឹក ១៦ លីត្រ។

ដោយអនុវត្តបាញ់២ដងយ៉ាងតិច មុនរដូវភ្លៀង (មួយសប្តាហ៍ម្តង)

**ខ.ការព្យាបាល**

- ចំពោះដើមកៅស៊ូមិនទាន់ចៀរជ័រ ប្រើថ្នាំប័រដូរតាមសមាមាត្រ៖

* សាច់ជូរខៀវ ១ គ.ក្រ + កំបោរស ៤ គ.ក្រ + ទឹក១០០លីត្រ ឬ

* ថ្នាំ Validamycine 5% ចំនួន ៥០ មីលីលីត្រ + ទឹក ១៦ លីត្រ

ដោយអនុវត្តលាបកន្លែងកើតជំងឺ ដោយត្រូវកោសសំបកផ្នែកខាងលើ និងផ្នែកខាងក្រោម ប្រហែល ៣០ ស.ម ដោយអនុវត្តយ៉ាងតិច ២ - ៣ ដង (មួយសប្តាហ៍ម្តង)។

- ចំពោះដើមកៅស៊ូដែលបានចៀរជ័ររួចហើយ៖

* បាញ់ ឬលាបថ្នាំ Validamycine 5% ចំនួន ៥០ មីលីលីត្រ + ទឹក ១៦ លីត្រ

* បាញ់ទ្រីដឺម័រហ្វ ២% (Tridemorph)

* បាញ់ ឬលាបថ្នាំ ប៉ាដាវីល ៨ - ១០ ម.ល + ទឹក ២០ លីត្រ ចំនួនពីរដង (១សប្តាហ៍ម្តង)

## ៤. វិធានការផ្សេងៗ

- ក្នុងករណីជំងឺធ្ងន់ធ្ងរ ត្រូវកាត់មែកដែលកើតជំងឺចេញ រួចប្រមូលដុតចោលឲ្យឆ្ងាយពីចម្ការ

- លាបប៉េត្រូឡាតូម (ខ្លាញ់គោ) នៅកន្លែងមុខកាត់

- នៅខាងក្រោមមុខកាត់ប្រវែង ២០ ៣០ ស.ម ត្រូវលាបប័រដូរខាប់ ឬ Validamycine 5%

- ផ្អាកចៀរនិងដាក់ជីបំប៉នស្របតាមបទដ្ឋានបច្ចេកទេស។